# តើមានសេវាអ្វីខ្លះសម្រាប់មនុស្សពេញវ័យ HRC?







HARBOR
REGIONAL
CENTER

ជាញឹកញាប់ អតិថិជនរបស់យើង ឬឪពុកម្តាយ/សមាជិកគ្រួសារបានស្នើសុំព័ត៌មានអំពីសេវាដែលមាន។ យើងបានរៀបចំបញ្ជីនេះដើម្បីផ្តល់ជូនអ្នកនូវទិដ្ឋភាពទូទៅអំពីសេវាទាំងនេះ។ សូមចងចាំថា សេវាត្រូវបានកំណត់ទៅតាមបុគ្គលម្នាក់ៗ។ សេវាត្រូវតែកំណត់ទៅតាមការចាំបាច់នៅលើផែនការផ្តោតលើបុគ្គល (IPP) និងត្រូវផ្តល់ជូនស្របទៅតាមគោលនយោបាយសេវារបស់មជ្ឈមណ្ឌលតំបន់ Harbor ដែលបានដាក់នៅលើវេបសាយត៍របស់យើង។

សេវាមួយចំនួនត្រូវបានផ្តល់ជូនដោយទីភ្នាក់ងារសហគមន៍ឧបត្ថម្ភដោយមូលនិធិសាធារណៈ ដូចជា Medi-Ca វិទ្យាល័យសហគមន៍ នាយកដ្ឋានស្តារនីតិសម្បទា។ល។ និងមួយចំនួនទៀតទទួលបានមូលនិធិពី HRC បន្ទាប់ពីយើងបានបំពេញតាមលក្ខខណ្ឌស្វែងរកធនធានមូលនិធិដែលអាចមានផ្សេងៗទៀតទាំងអស់។

យើងដឹងថា អ្នកចង់ដឹងអំពីប្រភេទសេវាផ្សេងៗដែលមានដើម្បីឲ្យអ្នកអាចក្លាយជាអ្នកចូលរួមដែលទទួលបានព័ត៌មានគ្រប់គ្រាន់នៅក្នុងដំណើរការរៀបចំផែនការសេវា។ ខាងក្រោមគឺជាបញ្ជីសេវា និងការគាំទ្រមួយចំនួនដែលជាទូទៅត្រូវបានណែនាំសម្រាប់មនុស្សពេញវ័យ (លែងចូលរៀននៅសាលារដ្ឋ) ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេផងដែរ។

# សេវាដែលផ្តល់ដោយបុគ្គលិក HRC

## ការវាយតម្លៃ និងការពិគ្រោះយោបល់

អ្នកសម្របសម្រួលសេវារបស់អ្នកអាចរៀបចំការជួបប្រជុំជាមួយអ្នកជំនាញរបស់ HRC ឬក្រុមពហុវិស័យដើម្បីវាយតម្លៃតម្រូវការរបស់អ្នក ក៏ដូចជាផ្តល់ជូនអ្នកនូវសេវាពិគ្រោះយោបល់ផងដែរ។ HRC មានអ្នកជំនាញដែលមានឯកទេសផ្នែក ចិត្តវិទ្យា ឥរិយាបថ សេនេទិច ការថែទាំ ការថែរក្សាមាត់ធ្មេញ ឱសថសាស្ត្រ អាហារូបត្ថម្ភ សុខភាពផ្លូវចិត្ត ការនិយាយ ការព្យាបាលដោយចលនា ការអប់រំច្បាប់ អត្ថប្រយោជន៍ផ្សេងៗ សេវាពេលថ្ងៃសម្រាប់មនុស្សធំ បច្ចេកវិទ្យាជំនួយ និងជម្រើសផ្សេងៗសម្រាប់ការរស់នៅ។

## ការគាំទ្រគ្រួសារ

នៅឯមជ្ឈមណ្ឌលតំបន់ Harbor យើងជឿជាក់ថា ប្រព័ន្ធគាំទ្រល្អប្រសើរគឺជាទ្រព្យសម្បត្តិដ៏សំខាន់សម្រាប់គ្រួសារ។ បណ្តាញព័ត៌មាន និងការគាំទ្រផ្តល់ជូនគ្រួសារនូវមូលដ្ឋានដ៏ល្អប្រសើរសម្រាប់ស្វែងរកប្រព័ន្ធសេវា ធ្វើការជ្រើសរើសក្រោយទទួលបានព័ត៌មានគ្រប់គ្រាន់ និងទទួលបានគុណភាពជីវិតកាន់តែល្អប្រសើរសម្រាប់គ្រួសារដែលស្ថិតក្នុងដំណាក់កាលវិវត្តទៅរកពិការភាព។ ការគាំទ្រត្រូវបានផ្តល់ជូននៅក្រោមរូបភាពក្រុមគាំទ្រឪពុកម្តាយ កម្មវិធីឪពុកម្តាយបង្ហាត់ឪពុកម្តាយនិងក្លិបបងប្អូន HRC។ សម្រាប់ព័ត៌មានលម្អិតអំពីជម្រើសគាំទ្រគ្រួសារទាំងនេះ សូមចូលមើលវេបសាយត៍របស់ HRC (www.harborrc.org/resources/family) ពិភាក្សាជាមួយអ្នកសម្របសម្រួលសេវារបស់អ្នក ឬអញ្ជើញទៅកាន់មជ្ឈមណ្ឌលធនធាននិងបច្ចេកវិទ្យាជំនួយរបស់ HRC នៅ Torrance ឬ Long Beach។

## បទបង្ហាញផ្តល់ព័ត៌មានសម្រាប់ឪពុកម្តាយ/គ្រួសារ

ថ្នាក់សិក្សា និងបទបង្ហាញផ្តល់ព័ត៌មានសម្រាប់គ្រួសារត្រូវបានផ្តល់ជូនរយៈពេលពេញមួយឆ្នាំដែលផ្តោតទៅលើប្រធានបទផ្សេងៗដូចជា ប្រាក់ចំណូលរបបសន្តិសុខជំនួយ (SSI) និងសេវាគាំទ្រតាមផ្ទះ (IHSS) ឥណទានតម្រូវការពិសេស ភាពជាអ្នកថែរក្សា ការកម្សាន្តក្នុងសង្គម និងការហាត់កាយសម្ព័ន្ធ ឱកាសផ្សេងៗ ជម្រើសសម្រាប់ការរស់នៅផ្សេងៗ។ល។ HRC ក៏ផ្តល់ជូនផងដែរនូវជំនួយសេវាបកប្រែ ការថែទាំកុមារ និងការធ្វើដំណើរនៅក្នុងការធ្វើបទបង្ហាញដែលបានកំណត់ ប្រសិនបើចាំបាច់ដើម្បីឲ្យអតិថិជន ឪពុកម្តាយ/អ្នកផ្តល់សេវាថែទាំអាចចូលរួមនៅក្នុងបទបង្ហាញផ្តល់ព័ត៌មានរបស់ HRC បាន។ បញ្ជីបទបង្ហាញនៅពេលខាងមុខអាចរកបាននៅក្នុងប្រតិទិនបណ្តុះបណ្តាល និងកម្មវិធីរបស់ HRC ក៏ដូចជានៅក្នុងប្រតិទិនវេបសាយត៍របស់យើងផងដែរ។

## ឱកាសសម្រាប់ភាពជាអ្នកដឹកនាំ

HRC ផ្តល់ជូននូវឱកាសស្ម័គ្រចិត្តសម្រាប់អតិថិជនជាមនុស្សពេញវ័យ និងសម្រាប់ឪពុកម្តាយ/សមាជិកគ្រួសារដើម្បីចូលរួមនៅក្នុងគណៈកម្មាធិការ HRC កម្មវិធីផ្សេងៗ ក៏ដូចជាភាពតំណាងទៅលើគណៈកម្មការប្រតិសិទ្ធិជនផងដែរ។

## មជ្ឈមណ្ឌលធនធាន និងបច្ចេកវិទ្យាជំនួយ

មជ្ឈមណ្ឌលធនធានរបស់ HRC ផ្តល់ជូននូវការគាំទ្រតាមរយៈការផ្តល់ព័ត៌មាន ការអប់រំ និងការបណ្តុះបណ្តាល បច្ចេកវិទ្យា និងតាមរយៈឪពុកម្តាយផ្សេងទៀត។

សេវារួមមានបណ្ណាល័យពហុប្រព័ន្ធ ផ្សព្វផ្សាយទូលំទូលាយ បន្ទប់អនុវត្តកុំព្យូទ័រ បន្ទប់បច្ចេកវិទ្យាជំនួយបណ្ណាល័យឲ្យខ្ចីប្រដាប់ប្រដាក្មេងលេង និងក្រុមគាំទ្រគ្រួសារ។

## ការសម្របសម្រួលសេវា

ការរៀបចំផែនការបុគ្គលជាមួយបុគ្គល និងគ្រួសារ ការបញ្ជូន ឬនិងការសម្របសម្រួលសេវាដែលមានពីទីភ្នាក់ងារសហគមន៍ ឬអ្នកផ្តល់សេវាដែលឧបត្ថម្ភមូលនិធិដោយមជ្ឈមណ្ឌលតំបន់ ការគាំទ្រសម្រាប់ការទទួលបានសេវាសមស្រប និងការពិនិត្យមើលជាប្រចាំយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ឬញឹកញាប់ជាងនេះប្រសិនបើចាំបាច់។

## ការឆ្លើយតបបន្ទាន់រយៈពេលម្ភៃបួនម៉ោង

HRC រក្សាប្រព័ន្ធឆ្លើយតបបន្ទាន់រយៈពេលម្ភៃបួនម៉ោង។ ប្រសិនបើអ្នកមានស្ថានភាពត្រូវការជំនួយបន្ទាន់ និងត្រូវការទាក់ទងទៅ HRC ក្រៅម៉ោងធ្វើការធម្មតា គឺនៅមានអ្នកចាំទទួលសំណើរបស់អ្នក។



# សេវានានាដែល HRC ទិញពីកម្មវិធី និងពេទ្យពិនិត្យជំងឺនៅក្នុងសហគមន៍

## កម្មវិធីសកម្មភាពពេលថ្ងៃរបស់មនុស្សពេញវ័យ

កម្មវិធីសកម្មភាពពេលថ្ងៃរបស់មនុស្សពេញវ័យផ្តល់នូវសកម្មភាពគាំទ្រពេលថ្ងៃដល់មនុស្សពេញវ័យដែលមិនអាចទទួលឲ្យប្រម្រើការងារបាន។ សកម្មភាពទាំងនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវឱកាសដាក់បញ្ចូលទៅក្នុងសហគមន៍ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន និងជម្រើសលក្ខណៈបុគ្គលសម្រាប់ការបណ្តុះបណ្តាលជំនាញរស់នៅរបស់មនុស្សធំ សកម្មភាពការងារ និងការស្ម័គ្រចិត្ត ការបង្ហាញអំពីអារម្មណ៍ផ្ទាល់ខ្លួន ការចូលរួមក្នុងសង្គម និងការគាំទ្រលើការព្យាបាលជំងឺ។
ជម្រើសនានារួមមាន មជ្ឈមណ្ឌលដាក់បញ្ចូលការដាក់បញ្ចូលដោយផ្អែក ការងារដោយផ្អែកសិល្បៈបែបច្នៃប្រឌិត និងកម្មវិធីព្យាបាលជាដើម។






## សេវាឥរិយាបថ

សេវាឥរិយាបថត្រូវបានរៀបចំឡើងដើម្បីជួយដល់ឪពុកម្តាយ/អ្នកផ្តល់សេវាថែទាំនៅក្នុងការអនុវត្តគោលការណ៍ឥរិយាបថ និងបង្រៀនជំនាញថ្មីៗដោយប្រើប្រាស់ឧទាហរណ៍លក្ខណៈបុគ្គល និងអនុវត្តជាក់ស្តែង។ វគ្គផ្សេងៗសម្រាប់ឪពុកម្តាយ និងក្មេងជំទង់ផ្តល់នូវឱកាសក្នុងការលើកកម្ពស់ការចូលរួមក្នុងសង្គម និងសុវត្ថិភាពនៅក្នុងសហគមន៍។ វគ្គផ្សេងៗសម្រាប់អតិថិជនជាមនុស្សពេញវ័យ និងគ្រួសាររបស់ពួកគេផ្តល់នូវឱកាសក្នុងការលើកកម្ពស់ការចូលរួមក្នុងសង្គម និងសុវត្ថិភាពនៅក្នុងសហគមន៍។

## ការត្រៀមសម្រាប់ការងារ

ថ្នាក់តម្រង់ទិសការងារ និងត្រៀមសម្រាប់ការងារត្រូវបានផ្តល់ជូនរយៈពេលពេញមួយឆ្នាំសម្រាប់មនុស្សពេញវ័យដែលមិនបានចូលរៀន និងចង់ស្វែងរកការងារ។ ដំណាក់កាលដំបូងឆ្ពោះទៅការស្វែងរកការងារតាមរយៈសេវាត្រៀមសម្រាប់ការងារគឺត្រូវចូលរួមនៅក្នុងការប្រជុំផ្តល់ព័ត៌មានតម្រង់ទិសការងារ។ វគ្គត្រៀមសម្រាប់ការងារបង្ហាត់នូវជំនាញផ្សេងៗដែលត្រូវការចាំបាច់ដើម្បីស្វែងរក និងទទួលបានការងារ។ សូមមើលការងារដែលទទួលបានការគាំទ្រ)

## ការរៀបចំផែនការសម្រាប់អនាគត

បុគ្គលិក HRC អាចផ្តល់ជំនួយដល់គ្រួសារមនុស្សចាស់ដើម្បីបង្កើតផែនការសម្រាប់ការថែទាំ និងការគាំទ្រនាពេលអនាគត។

## សេវាបកប្រែផ្ទាល់មាត់ និងបកប្រែឯកសារ

HRC អាចផ្តល់សេវាបកប្រែផ្ទាល់មាត់នៅក្នុងការប្រជុំជាមួយ HRC និងការបកប្រែសំណៅឯកសារ (ផែនការសេវាបុគ្គល/គ្រួសារ និងផែនការផ្តោតលើបុគ្គល) ពីភាសាអង់គ្លេសទៅជាភាសាកំណើតរបស់អតិថិជន/គ្រួសារ។

## ជម្រើសសម្រាប់ការរស់នៅ

### ការបណ្តុះបណ្តាលអំពីការរស់នៅដោយខ្លួនឯង

សម្រាប់មនុស្សពេញវ័យដែលឈប់រៀន និងត្រៀមខ្លួនដើម្បីរស់នៅដោយខ្លួនឯង HRC ផ្តល់នូវការវាយតម្លៃបុគ្គល និងការបណ្តុះបណ្តាលតាមមណ្ឌលអំពីជំនាញរស់នៅដោយខ្លួនឯង។

### ការគាំទ្រមនុស្សពេញវ័យតាមផ្ទះ

សម្រាប់មនុស្សពេញវ័យដែលរស់នៅជាមួយសមាជិកគ្រួសារជាមនុស្សចាស់ មានជំងឺ ឬមិនអាចផ្តល់រាល់ការគាំទ្រដែលត្រូវការចាំបាច់ នោះសេវាគាំទ្រតាមផ្ទះអាចផ្តល់ជូនដើម្បីជួយនៅក្នុងការភ្ជាប់ទំនាក់ទំនងជាមួយធនធានសហគមន៍ និងរក្សាសុខុមាលភាពរបស់អតិថិជនជាមនុស្សពេញវ័យ។

### ផ្ទះមានអាជ្ញាប័ណ្ណ

សម្រាប់មនុស្សពេញវ័យដែលមិនអាចរស់នៅជាមួយគ្រួសារ ឬរស់នៅដោយខ្លួនឯងបាន ផ្ទះមានអាជ្ញាប័ណ្ណផ្តល់នូវការថែទាំផ្ទាល់ ការគាំទ្រលើផ្នែកសុខភាព និងឥរិយាបថ និងផ្ទះប្រកបដោយផាសុកភាពនៅក្នុងសហគមន៍។

### សេវារស់នៅដោយមានការគាំទ្រ

សម្រាប់មនុស្សពេញវ័យដែលលែងរស់នៅជាមួយគ្រួសាររបស់ខ្លួននោះ សេវារស់នៅដោយមានការគាំទ្រជួយអតិថិជនឲ្យកាន់តែមានភាពម្ចាស់ការនៅពេលដែលពួកគេរស់នៅក្នុងសហគមន៍ដោយខ្លួនឯងផ្ទាល់។ សេវានេះអាចរួមមានជំនួយដើម្បីទទួលបានជម្រើសលំនៅដ្ឋានដែលមានតម្លៃសមរម្យ។

## សេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងថែទាំ

ដើម្បីបំពេញតម្រូវការសេវាវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងថែទាំសម្រាប់អតិថិជនដែលពុំមានធនធានថែទាំសុខភាពផ្សេងទៀតដូចជាធានារ៉ាប់រងឯកជន ឬ Medi-Calនោះនឹងអាចមានការផ្តល់ជំនួយតាមការចាំបាច់។ ការវាយតម្លៃលើការថែទាំ ឬការថែទាំសុខភាពតាមផ្ទះអាចផ្តល់ជូនដើម្បីគាំទ្រអតិថិជន ឬគ្រួសារនៅក្នុងការបំពេញតម្រូវការថែទាំសុខភាពពិសេស។

## បរិក្ខារ និងសម្ភារវេជ្ជសាស្ត្រ

HRC អាចផ្តល់ការវាយតម្លៃទៅលើតម្រូវការវេជ្ជសាស្ត្រ និងផ្តល់ជំនួយនៅក្នុងការកំណត់ធនធានសហគមន៍ផ្សេងៗដូចជា Medi-Cal ជាដើម។ ប្រសិនបើពុំមានធនធានទាំងនេះទេ យើងអាចចូលរួមចំណែកនៅក្នុងការទិញសម្ភារ និងបរិក្ខារផ្សេងៗ ដូចជាកៅអីរុញ គ្រែបច្ចេកទេសជាដើម។ល។



## ការធ្វើដំណើរ

HRC ផ្តល់នូវការវាយតម្លៃជំនាញធ្វើដំណើរ ការបណ្តុះបណ្តាល និងការបញ្ជូនដល់អតិថិជនជាមនុស្សពេញវ័យដើម្បីគាំទ្រពួកគេនៅក្នុងការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈដើម្បីធ្វើដំណើរទៅ និងមក ពីទីកន្លែងធ្វើការ ឬទីតាំងបណ្តុះបណ្តាលពេលថ្ងៃ។

## ជំនួយផ្ទាល់ខ្លួន

នៅក្នុងស្ថានភាពមួយចំនួន ជំនួយផ្ទាល់ខ្លួនអាចផ្តល់ជូនដើម្បីគាំទ្រដល់មនុស្សពេញវ័យដែលមានតម្រូវរូបវន្ត នឹងវេជ្ជសាស្រ្តខ្ពស់។



## ការគាំទ្រក្រោយបញ្ចប់វិទ្យាល័យ

កម្មវិធីពីវិទ្យាល័យទៅអាជីពការងារ (College 2 Career program) ផ្តល់ជូនសិស្សនូវឱកាសទទួលបានបទពិសោធន៍ជីវិតសិក្សានៅវិទ្យាល័យ និងសម្រេចបានគោលដៅអប់រំ និងអភិវឌ្ឍន៍ក្រោយបញ្ចប់វិទ្យាល័យរបស់ពួកគេ។ អ្នកចូលរួមក្នុងកម្មវិធីនេះទទួលបានការគាំទ្រលក្ខណៈបុគ្គលផ្សេងៗ ដូចជា លំនៅដ្ឋានសម្រាប់សិស្សដែលទទួលបានការគាំទ្រ ការឧបត្ថម្ភលើការសិក្សា និងការចូលរួមនៅក្នុងសកម្មភាពវិទ្យាល័យទូទៅ នៅពេលពួកគេខិតខំសិក្សាឆ្ពោះទៅកម្មវិធីកម្រិត ឬសញ្ញាប័ត្រដើម្បីទទួលបានការងារ។ បច្ចុប្បន្នកម្មវិធីនេះមានផ្តល់ជូននៅ LBCC។

សិស្សដែលចូលរៀននៅវិទ្យាល័យផ្សេងទៀតអាចទទួលបានការគាំទ្រពីសេវាសិស្សពិការដែលផ្តល់ ជូនដោយសាលាដូចជាជំនួយលើការចុះឈ្មោះ ការពិគ្រោះយោបល់ អ្នកធ្វើកំណត់ហេតុបច្ចេកវិទ្យាកុំព្យូទ័រជំនួយ។ល។ ប្រសិនបើសិស្សត្រូវការជំនួយផ្ទាល់ខ្លួនដើម្បីគាំទ្រសកម្មភាពរស់នៅប្រចាំថ្ងៃពេលសិក្សានៅសាលា HRC អាចជួយតាមរយៈការផ្តល់ការគាំទ្រនេះ។

## អ្នកតំណាងទទួលប្រាក់/ការគ្រប់គ្រងប្រាក់

សម្រាប់អតិថិជន/គ្រួសារដែលមិនអាចគ្រប់គ្រងអត្ថប្រយោជន៍ប្រចាំខែដែលទទួលបានពីរបបសន្តិសុខសង្គមបាន HRC អាចផ្តល់សេវាអ្នកតំណាងទទួលប្រាក់។

## ការថែទាំជំនួសបណ្តោះអាសន្ន

ជំនួយបណ្តោះអាសន្នពីការថែទាំ និងគ្រប់គ្រងអាចផ្តល់ជូនដល់ឪពុកម្តាយ ឬអ្នកផ្តល់សេវាថែទាំបឋមផ្សេងៗទៀតសម្រាប់អតិថិជនដែលមានកង្វះខាតធំក្នុងការថែទាំខ្លួន តម្រូវការវេជ្ជសាស្រ្តជាប្រចាំ ឬបញ្ហាឥរិយាបថផ្សេងៗ។ សេវាថែទាំជំនួសបណ្តោះអាសន្នត្រូវបានផ្តល់ជូននៅតាមផ្ទះរបស់អតិថិជន/គ្រួសារដោយទីភ្នាក់ងារថែទាំតាមផ្ទះជាប់កិច្ចសន្យា។ នៅក្នុងការថែទាំជំនួសបណ្តោះអាសន្នកំណត់ដោយគ្រួសារ សមាជិកគ្រួសារអាចបញ្ជូនទៅមិត្តភក្តិ ឬសាច់ញាតិដែលខ្លួនទុកចិត្តដែលបម្រើការងារឲ្យទីភ្នាក់ងារថែទាំតាមផ្ទះ ដើម្បីផ្តល់ការថែទាំជំនួសបណ្តោះអាសន្នសម្រាប់សមាជិកគ្រួសាររបស់អ្នក។ កាថែទាំជំនួសបណ្តោះអាសន្នក្រៅផ្ទះអាចផ្តល់ជូននៅតាមផ្ទះដែលមានអាជ្ញាប័ណ្ណ ប្រសិនបើមាន។

## ការងារដែលទទួលបានការគាំទ្រ

សេវាការងារដែលទទួលបានការគាំទ្រផ្តល់នូវសេវា និងការគាំទ្រលក្ខណៈបុគ្គលសម្រាប់មនុស្សពេញវ័យដែលឈប់ពីសាលា និងត្រៀមខ្លួនចាប់ផ្តើមស្រាវជ្រាវការងាររបស់ខ្លួន។ សេវាការងារដែលទទួលបានការគាំទ្ររួមមានការវាយតម្លៃជំនាញ និងចំណាប់អារម្មណ៍បុគ្គលកាអភិវឌ្ឍ នឹងការដាក់ការងារលក្ខណៈបុគ្គល (ទាំងជាលក្ខណៈបុគ្គល ឬជាក្រុម) និងការបណ្តុះបណ្តាលពេលកំពុងបំពេញការងារដើម្បីលើកកម្ពស់ការងារប្រកបដោយជោគជ័យ។ សេវាទាំងនេះមានផ្តល់ជូនដោយសហការជាមួយនាយកដ្ឋានស្តារនីតិសម្បទា។

## មធ្យោបាយដឹកជញ្ជូន

HRC នឹងធ្វើការវាយតម្លៃ និងដោយផ្អែកលើតម្រូវការ និងសមត្ថភាពបុគ្គល ជួយភ្ជាប់អតិថិជនជាមនុស្សពេញវ័យទៅនឹងសេវាដឹកជញ្ជូនសមស្របផ្សេងៗ ដូចជាសេវាដឹកជញ្ជូនសាធារណៈ សេវាដឹកជញ្ជូនរួមរបស់សហគមន៍ និងអ្នកផ្តល់សេវាជាប់កិច្ចសន្យាជាមួយមជ្ឈមណ្ឌលតំបន់ជាដើម។ ពេលខ្លះយើងទាក់ទងជាមួយឪពុកម្តាយ/សមាជិកគ្រួសារដើម្បីសេវាដឹកជញ្ជូននៅពេលដែលការធ្វើបែបនេះជាជម្រើសដែលមានផលចំណេញ។

HARBOR REGIONAL CENTER
HARBOR DEVELOPMENTAL DISABILITIES FOUNDATION, INC.
21231 HAWTHORNE BLVD., TORRANCE, CA 90503
(310) 540-1711 • www.harborrc.org